**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៨ ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលសមាសភាពគណៈកម្មការបង្ក្រាបបទល្មើសនានា និងត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្តោយព្រំដែនសមុទ្រកម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញប្រកាសលេខ ០១ ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ

-បានឃើញប្រកាសលេខ ០២ ប្រក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យជលផល

-បានឃើញសេចក្តីសម្រេចលេខ ៧២សសរ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មការបង្ក្រាបបទល្មើសនានានិងត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង

-យោងការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១៖** ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការ ដើម្បីបង្ក្រាបបទល្មើសនានា និងត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្តោយព្រំដែនសមុទ្រកម្ពុជា- ថៃ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-លោកជំទាវ មិថុនា ភូថង | អភិបាល នៃគណៈអភិបាលខេត្តកោះកុង | ប្រធាន |
| ២-ឯកឧត្តម លី យ៉ុងផាត់ | ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-ឧត្តមសេនីយ៍ឯក យឿង សុខុន | មេបញ្ជាការយោធភូមិភាគទី៣ | អនុប្រធាន |
| ៤-ឧត្តមនាវីឯក ទៀ សុខា | មេបញ្ជាការរងកងទ័ពជើងទឹក | អនុប្រធាន |
| ៥-ឧត្តមសេនីយ៍ឯក តេង សួន | ប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនទឹក | អនុប្រធាន |
| ៦-លោក ពុំ សុថា | នាយអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | អនុប្រធាន |
| ៧-លោកមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តកោះកុង | | សមាជិក |
| ៨-លោកមេបញ្ជាការកងរាជអាវុធហត្ថខេត្តកោះកុង | | សមាជិក |
| ៩-លោកស្នងការនគរបាលខេត្តកោះកុង | | សមាជិក |
| ១០-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង | | សមាជិក |
| ១១-លោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកោះកុង | | សមាជិក |
| ១២-លោកប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកោះកុង | | សមាជិក |
| ១៣-លោកប្រធានមន្ទីរពាណិជ្ជកម្មខេត្តកោះកុង | | សមាជិក |
| ១៤-លោកប្រធានសាខាគយ និងរដ្ឋាករខេត្តកោះកុង | | សមាជិក |
| ១៥-លោកប្រធានសាខាកាំកុងត្រូលប្រចាំខេត្តកោះកុង | | សមាជិក |

**ប្រការ ២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ១៥ រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ